# ទិដ្ឋភាពទូទៅនៃកម្មវិធី ៖
# គម្រោងមូលនិធិ «ចល័ត» ២០២៦
# កម្មវិធី៖ មូលនិធិ

## ១. តើកម្មវិធីនេះមានប្រតិបត្តិការដូចម្តេច ?

គម្រោងមូលនិធិ «ចល័ត» គឺជាគម្រោងស្នូលមួយនៅក្នុងកម្មវិធីមូលនិធិនៃអង្គការសិល្បៈខ្មែរអមតៈ។ ជារៀងរាល់ឆ្នាំ យើងតែងតែផ្តល់ឱកាសនេះដល់សិល្បករ និងអ្នកធ្វើការក្នុងវិស័យសិល្បៈវប្បធម៌គ្រប់ទម្រង់ ដើម្បីអភិវឌ្ឍគំនិត និងចំណេះដឹង ផ្លាស់ប្តូរបទពិសោធន៍ កសាងបណ្តាញ និងពង្រឹងសមត្ថភាពក្នុងជំនាញរបស់ខ្លួន តាមរយៈការទៅចូលរួមផ្សេងៗនៅប្រទេសនានាក្នុងតំបន់អាស៊ី។

បេក្ខជនដែលចាប់អារម្មណ៍ចង់ទទួលបានឱកាសគាំទ្រនេះ ត្រូវបំពេញទម្រង់ស្នើសុំដែលយើងបានភ្ជាប់ជាមួយនឹងសេចក្តីប្រកាស ដើម្បីបង្ហាញពីឆន្ទៈ និងអត្ថប្រយោជន៍ដែលខ្លួនរំពឹងទុកពីកម្មវិធី។ បន្ទាប់មក គណៈកម្មការឯករាជ្យនៃគម្រោងមូលនិធិនេះនឹងវាយតម្លៃលើពាក្យស្នើសុំរបស់អ្នក ហើយដាក់ពិន្ទុដើម្បីកំណត់ជ្រើសរើសបេក្ខជនជ័យលាភីសម្រាប់កម្មវិធីនេះ។

## ២. តើគោលដៅរបស់កម្មវិធីមានអ្វីខ្លះ ?

កម្មវិធីនេះមានគោលដៅចង់ជួយគាំទ្រការអភិវឌ្ឍសមត្ថភាពសិល្បករ អ្នកស្រាវជ្រាវ ឬអ្នកស្រាវជ្រាវវប្បធម៌ តាមរយៈការផ្តល់មូលនិធិឱ្យពួកគេទៅចូលរួមក្នុងកម្មវិធីវគ្គបណ្តុះបណ្តាល សិក្ខាសាលា សន្និសីទ មហោស្រព ការធ្វើបទបង្ហាញពីលទ្ធផលស្រាវជ្រាវ និងកម្មវិធីនិវេសនដ្ឋានសិល្បៈជាដើម។ យើងជឿជាក់ថា ការចូលរួមជ្រោមជ្រែងលើការអភិវឌ្ឍសមត្ថភាពធនធានមនុស្សក្នុងវិស័យសិល្បៈ ជាចលករដ៏ចាំបាច់មួយដែលចូលរួមចំណែកក្នុងការពង្រឹងប្រព័ន្ធអេកូសិល្បៈនៅកម្ពុជា។

## ៣. តើអត្ថប្រយោជន៍នៃកម្មវិធីនេះមានអ្វីខ្លះ ?

- បេក្ខជនជ័យលាភីអាចទទួលបានមូលនិធិរហូតដល់១០០០ ដុល្លារ ដើម្បីរ៉ាប់រងលើការធ្វើដំណើរ ការស្នាក់នៅ អាហារ និងតម្លៃចុះឈ្មោះផ្សេងៗ
- មានឱកាសបង្ហាញលទ្ធផលស្រាវជ្រាវ ឬស្នាដៃ តាមរយៈវិធានសិល្បៈរបស់ខ្លួន
- មានឱកាសពង្រីកចំណេះដឹង និងកសាងបណ្តាញជាមួយនឹងអ្នកដែលធ្វើការក្នុងវិស័យស្រដៀងគ្នានៅក្នុងតំបន់អាស៊ី

## ៤. តើនរណាជាអ្នកចូលរួមគោលដៅសម្រាប់កម្មវិធីនេះ ?

- សិល្បករ និងអ្នកធ្វើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌គ្រប់ទម្រង់ (ដូចជា៖ ភាពយន្ត

សិល្បៈទស្សនីយភាព សិល្បៈសូនរូប សហគមន៍អ្នកនិពន្ធ។ល។

*ដើម្បីមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់មូលនិធិនេះ អ្នកត្រូវ៖*

- *មូលនិធិនេះគឺសម្រាប់តែអ្នកដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិកម្ពុជា លិខិតឆ្លងដែន ឬទិដ្ឋាការ K Visa ប៉ុណ្ណោះ។*

## ៥. តើលក្ខខណ្ឌជ្រើសរើសសម្រាប់កម្មវិធីនេះ មានអ្វីខ្លះ ?

លក្ខខណ្ឌដែលនឹងប្រើប្រាស់ដើម្បីជ្រើសរើសមូលនិធិនេះ មានដូចជា ៖

1. អ្នកត្រូវបំពេញលើពាក្យស្នើសុំដែលផ្តល់ដោយអង្គការសិល្បៈខ្មែរអមតៈ។ សូមភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធផ្សេងៗ ដែលយើងបានតម្រូវ។ អ្នកអាចបំពេញពាក្យស្នើសុំជាភាសាខ្មែរ ឬអង់គ្លេស ឬថតចម្លើយជាវីដេអូ វីសំឡេងក៏បាន
2. អ្នកអាចបំពេញពាក្យស្នើសុំដោយដៃ ឬដោយកុំព្យូទ័រ។ ប្រសិនបើអ្នកជួបការលំបាកក្នុងការបំពេញពាក្យស្នើសុំ សូមទាក់ទងមកលេខទូរស័ព្ទ ០៧៧ ៥៥ ៨៥ ៤៥ ។
3. អ្នកអាចបំពេញពាក្យនេះសម្រាប់ខ្លួនឯង ឬសម្រាប់ក្រុម។ ក្នុងករណីអ្នកបំពេញសម្រាប់ក្រុម សូមបញ្ជាក់តែឈ្មោះតែប្រធានក្រុម ឬអ្នកតំណាងក្រុម។
4. អ្នកត្រូវបង្ហាញពី៖
   - ការប្តេជ្ញាចិត្តរបស់អ្នកក្នុងការទៅចូលរួមកម្មវិធី
   - ចំណាប់អារម្មណ៍របស់អ្នកអំពីសារៈសំខាន់នៃកម្មវិធី/ដំណើរការសិក្សាស្រាវជ្រាវក្នុងការជួយបន្ថែមគំនិត បទពិសោធន៍ ចំណេះដឹង និងការអភិវឌ្ឍវិស័យសិល្បៈ
   - មានការប្តេជ្ញាចិត្តក្នុងការសរសេររបាយការណ៍សង្ខេបអំពីបទពិសោធន៍ និងចំណេះដឹងដែលអ្នកទទួលបានពីកម្មវិធី
   - ឆន្ទៈក្នុងការរៀបចំជំនួបមួយ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍ដែលទទួលបានពីការចូលរួម ជាមួយក្រុម សហគមន៍សិល្បៈ និងក្រុមគោលដៅផ្សេងៗទៀតដែលអ្នកគិតថាទាញប្រយោជន៍ពីការចូលរួមក្នុងជំនួបចែករំលែកនេះ

**គោលការណ៍អាទិភាព៖**

អង្គការសិល្បៈខ្មែរអមតៈលើកទឹកចិត្តដល់សហគមន៍ដែលមានសំឡេងតិច រួមមាន៖ សហគមន៍ជនជាតិដើម អ្នកមានពិការភាព ស្ត្រី និងអ្នកដែលមិនធ្លាប់បានទទួលឱកាសទាំងនេះពីមុន មកឱ្យដាក់ពាក្យស្នើសុំ។ គួរបញ្ជាក់ផងដែរថា អាទិភាពចម្បងនឹងផ្តល់ជូនទៅកាន់បេក្ខភាពជាស្ត្រីចំនួនមួយកន្លែង។

## ៦. តើដំណើរការនៃការជ្រើសរើសសម្រាប់កម្មវិធីនេះ មានអ្វីខ្លះ ?

- នៅពេលអ្នកផ្ញើពាក្យស្នើសុំមកកាន់ពួកយើង ពួកយើងនឹងបញ្ជាក់ប្រាប់ទៅអ្នកវិញ ប្រសិនបើពួកយើងបានទទួល ។ ប្រសិនបើអ្នកមិនបានទទួលដំណឹងពីពួកយើងក្នុងអំឡុងពេល ៣ ថ្ងៃនៃថ្ងៃធ្វើការទេ សូមទាក់ទងមកពួកយើងម្តងទៀត ។
- ពាក្យស្នើសុំទាំងអស់ដែលត្រឹមត្រូវតាមលក្ខខណ្ឌ នឹងត្រូវបានពិនិត្យម្តងទៀតដោយយោងទៅតាមលក្ខខណ្ឌនៃការជ្រើសរើសដែលបានកំណត់ខាងលើ ។

- ការពិនិត្យមើលនេះ នឹងត្រូវបានធ្វើឡើងដោយគណៈកម្មការជ្រើសរើសឯករាជ្យមួយរូប (ឬលើសពីនេះ)
- គណកម្មការនឹងប្រើប្រព័ន្ធដាក់ពិន្ទុ ដើម្បីធ្វើឱ្យប្រាកដថាការផ្ទៀងផ្ទាត់ពាក្យស្នើសុំមានភាពត្រឹមត្រូវ និងជាក់លាក់

- បេក្ខជនដែលបានជាប់ដល់ដំណាក់កាលពិនិត្យពាក្យស្នើសុំនឹងទទួលបានការអញ្ជើញចូលរួមវគ្គសម្ភាស
- បេក្ខជនត្រូវបញ្ជូនសំណើមកកាន់អ្នកសម្របសម្រួលកម្មវិធីយ៉ាងហោចណាស់ ១ ខែ មុនពេលធ្វើដំណើរ ប៉ុន្តែយើងសូមលើកទឹកចិត្តអ្នកឱ្យមុននេះ ប្រសិនបើអ្នកដឹងពីឱកាសនោះជាមុន ។
- ក្នុងករណីដែលអ្នកបញ្ជូនពាក្យស្នើសុំត្រូវក្នុងរយៈពេលតិចជាងមួយខែ អ្នកត្រូវបង្ហាញភស្តុតាងសមរម្យ ឧ. លិខិតពន្យល់ពីអ្នកអញ្ជើញ។ ទោះជាបែបនេះក្តី យើងមិនធានានូវភាពជោគជ័យនៃការស្នើសុំនេះទេ ព្រោះមានតែគណៈកម្មការឯករាជ្យប៉ុណ្ណោះដែលមានសិទ្ធិសម្រេច។

## ៧. តើពេលវេលាអនុវត្តគម្រោងត្រូវស្ថិតក្នុងចន្លោះពេលណា?

អ្នកត្រូវប្រាកដថា កម្មវិធីរបស់អ្នកត្រូវប្រព្រឹត្តឡើងនៅចន្លោះខែមករា ដល់ធ្នូ ឆ្នាំ ២០២៦

## ៨. តើនរណាជាអ្នកសម្របសម្រួលកម្មវិធីនេះ?

ក្រុមការងារអង្គការសិល្បៈអមតៈនឹងសម្របសម្រួលកម្មវិធីនេះ រួមមាន កញ្ញា សាយ តុលា ជាអ្នកសម្របសម្រួលកម្មវិធីមូលនិធិ និង កញ្ញា យ៉ុន សុខខន ជានាយិកាប្រតិបត្តិ។

## ៩. កាលបរិច្ឆេទសំខាន់ៗ

| កាលបរិច្ឆេទ | សកម្មភាព |
|---|---|
| ការបរិច្ឆេទទួលពាក្យស្នើសុំ | ចាប់ទទួលពាក្យពីខែមករា ដល់ធ្នូ ឆ្នាំ ២០២៦ |
| ចំនួនបេក្ខជនជ័យលាភី | ២ រូប (នឹងផ្តល់ជូនក្នុងខែផ្សេងគ្នា) |
| សុពលភាពនៃការបញ្ជូនសំណើ | យ៉ាងហោចណាស់ ១ ខែ មុនពេលធ្វើដំណើរ |
| ការឆ្លើយតបលទ្ធផល | រយៈពេល ១០ ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពេលដាក់ពាក្យ |